ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ៖ ..........✓.............. ព.ម.

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិព័រណ៍រូបថត អបអរខួប ៦៥ឆ្នាំ នៃទំនាក់ទំនងការទូតកម្ពុជា-គុយបា

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៦– អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP) នៃក្រសួងព័ត៌មាន បានសហការជាមួយស្ថានឯកអគ្គរដ្ឋទូតគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងការរៀបចំពិព័រណ៍រូបថត នៅសាលចតុម្មុខមង្គល ទីស្តីការក្រសួងព័ត៌មាន នៅថ្ងៃនេះ ដើម្បីអបអរសាទរខួប ៦៥ឆ្នាំ នៃទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋគុយបា (១៩៦០-២០២៥)។

ពិធីនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន និង **លោកជំទាវ** Milena Caridad Zaldívar Piedra ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋគុយបាប្រចាំនៅកម្ពុជា ដោយមានការអញ្ជើញចូលរួមពីតំណាងមកពីរដ្ឋសភា ក្រសួង-ស្ថាប័ននានា អង្គទូតបរទេសប្រចាំនៅកម្ពុជា និងតំណាងស្ថាប័នជាតិ-អន្តរជាតិ សរុបចំនួនប្រមាណ ២០០នាក់។

រូបថតចំនួន ៣១សន្លឹក ត្រូវបានជ្រើសរើសយកមកតាំងបង្ហាញក្នុងពិធីនេះ ដោយរំលេចអំពីពេលវេលា និងសមិទ្ធផលសំខាន់ៗ ដែលឆ្លុះបញ្ចាំងពីមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏យូរអង្វែងរវាងប្រទេសទាំងពីរ ក្នុងរយៈពេលជាង ៦ទសវត្សរ៍មកនេះ ដោយចំណងមិត្តភាពដ៏រឹងមាំនេះ ឈរលើមូលដ្ឋាននៃការគោរពគ្នាទៅវិញទៅមក សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ រួមមាន សុខាភិបាល អប់រំ ការទូត វប្បធម៌ កីឡា និងព័ត៌មាន។

ថ្លែងក្នុងពិព័រណ៍នេះ **ឯកឧត្តម** នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានរំលឹកអំពីសារៈសំខាន់ជាប្រវត្តិសាស្ត្រនៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ចាប់តាំងពីថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៦០ ក្រោមព្រះរាជតម្រិះផ្តួចផ្តើមរបស់ **សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** និង **ឯកឧត្តម** Fidel Castro អគ្គមគ្គុទេសក៍បដិវត្តន៍គុយបា។ ឯកឧត្តមក៏បានឆ្លៀតឱកាសសម្តែងនូវការដឹងគុណចំពោះគុយបា ដែលបានផ្តល់ការគាំទ្រយ៉ាងមានតម្លៃដល់កម្ពុជា ជាពិសេសក្នុងវិស័យសុខាភិបាល និងការអភិវឌ្ឍធនធានមនុស្ស ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការកសាង និងភាពរីកចម្រើនរបស់កម្ពុជា នាពេលកន្លងមក។

ឯកឧត្តមរដ្ឋមន្ត្រីបានមានប្រសាសន៍ថា *«រូបថតដែលដាក់តាំងបង្ហាញនៅក្នុងការតាំងពិព័រណ៍នេះឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រ និងសមិទ្ធផលដែលកើតចេញពីទំនាក់ទំនងជិតស្និទ្ធរវាងប្រទេសយើងទាំងពីរ»*។ នៅក្នុងបរិបទនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ឯកឧត្តមរដ្ឋមន្ត្រីបានគូសបញ្ជាក់អំពីទំនាក់ទំនងដ៏រឹងមាំរវាង

Ch

កម្ពុជា និងគុយបា នៅក្នុងវិស័យព័ត៌មាន ដោយផ្តោតជាសំខាន់លើការផ្លាស់ប្តូរព័ត៌មាន ការផ្សព្វផ្សាយវប្បធម៌នៃប្រទេសទាំងពីរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់អ្នកសារព័ត៌មាន។ ឯកឧត្តមបានបង្ហាញពី *«គោលជំហរដ៏រឹងមាំរបស់ក្រសួងព័ត៌មានក្នុងការពង្រឹងទំនាក់ទំនងជាមួយគុយបាឱ្យកាន់តែរឹងមាំ ដើម្បីជាប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំងពីរ ជាពិសេសក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយឆ្លងដែន ក្នុងបរិបទនៃការរីកចម្រើនបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត»*។

ក្នុងពិធីនេះដែរ លោកជំទាវ Milena Caridad Zaldívar Piedra ឯកអគ្គរដ្ឋទូតគុយបាប្រចាំព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ពីទំនាក់ទំនងប្រពៃណីដ៏រឹងមាំរវាងគុយបា និងកម្ពុជា ដោយកត់សម្គាល់ថាទំនាក់ទំនងទ្វេភាគីនេះ នៅតែបន្តឈរលើគោលការណ៍រួម ការយោគយល់គ្នាទៅវិញទៅមក និងការប្តេជ្ញាចិត្តរួមគ្នាចំពោះសន្តិភាព និងច្បាប់អន្តរជាតិ។ លោកជំទាវ ឯកអគ្គរដ្ឋទូតបានមានប្រសាសន៍ថា៖ *«អស់រយៈពេលជាង ៦៥ឆ្នាំមកនេះ ប្រទេសគុយបា និងប្រទេសកម្ពុជា បានពង្រឹងទំនាក់ទំនងពិសេស និងជាប្រពៃណី ដោយផ្អែកលើគោលការណ៍រួមដ៏រឹងមាំ ការគោរពគ្នាទៅវិញទៅមក និងការយោគយល់គ្នា ក៏ដូចជាការការពារសន្តិភាព និងបុព្វហេតុត្រឹមត្រូវ ក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិ។»*

លោកជំទាវបានបន្តថា ពេលវេលាដ៏គួរឱ្យកត់សម្គាល់នៃចំណងមិត្តភាពជិតស្និទ្ធទាំងនេះ ត្រូវបានបង្ហាញនៅក្នុងរូបថតនៃការតាំងពិព័រណ៍ ដែលរៀបចំដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា និងស្ថានទូតគុយបា ដែលជាមរតកនៃមិត្តភាព និងសាមគ្គីភាពជាប្រវត្តិសាស្ត្រសម្រាប់ប្រជាជនគុយបា និងប្រជាជនកម្ពុជា ជំនាន់បច្ចុប្បន្ន និងអនាគត។

ពិព័រណ៍រូបថតនេះ គឺជាការរំលឹកដល់មិត្តភាពជាប្រវត្តិសាស្ត្ររវាងប្រទេសទាំងពីរ និងជាការបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តរួម ក្នុងការពង្រឹងទំនាក់ទំនងទ្វេភាគីបន្ថែមទៀត ដើម្បីផលប្រយោជន៍របស់ប្រជាជនប្រទេសទាំងពីរ៕

ថ្ងៃអង្គារ ៥កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៦

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក ថាច់ ផាណារ៉ុង អគ្គនាយករងទីភ្នាក់ងារសារព័ត៌មានកម្ពុជា
លេខទូរស័ព្ទ/តេឡេក្រាម៖ +៨៥៥ ៩៩ ៩១៧ ៧៨៨